**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ៤៧០៧ សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

ក្រសួងមហាផ្ទៃ មានកិត្តិយសសូមជូនដំណឹងដល់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងមហាផ្ទៃនឹងចាត់មន្ត្រីជំរឿនដើម្បីចុះធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិត និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ចាប់ផ្តើមពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ នៅតាមអាសយដ្ឋានទីស្នាក់ការកណ្តាលរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃសូមស្នើដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីជំរឿនក្នុងការបំពេញព័ត៌មានលើសលាកបត្រឱ្យបានត្រឹមត្រូវច្បាស់លាស់ និងជំរុញឱ្យការធ្វើជំរឿននេះទទួលបានលទ្ធផលល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
**ក្រសួងមហាផ្ទៃ**

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh